ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ៥៨.១២.០១៩...០០៥ ផ្សព្វផ្សាយព័ត៌មាន

ថ្ងៃព្រហស្បតិ៍ ៩កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែមីនា ឆ្នាំ២០១៩

# សេចក្តីប្រកាសព័ត៌មាន
## ពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការយុទ្ធសាស្ត្រជាតិ
## ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ឆ្នាំ២០១៩-២០២៣

នៅថ្ងៃព្រហស្បតិ៍ ៩កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៩ នៅសណ្ឋាគារ សូហ្វីតែល ភ្នំពេញ ភូគីត្រា អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាបានរៀបចំពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការយុទ្ធសាស្ត្រជាតិស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ឆ្នាំ២០១៩-២០២៣ ក្រោមអធិបតីភាព ឯកឧត្តម **ជា ចាន់តូ** ទេសាភិបាលធនាគារជាតិនៃកម្ពុជា និងជាប្រធាន គ.ស.ហ និង លោក Clive Scott ទីប្រឹក្សាជាន់ខ្ពស់របស់មូលនិធិរូបិយវត្ថុអន្តរជាតិ។ ភ្ញៀវជាតិនិងអន្តរជាតិចូលរួមក្នុងពិធីសម្ពោធនេះ សរុបប្រមាណ ៤០០នាក់ មកពីក្រសួង-ស្ថាប័ន អង្គការជាតិនិងអន្តរជាតិ ស្ថានទូត គ្រឹះស្ថានធនាគារនិងវិស័យឯកជន។

ក្រុមការងារបច្ចេកទេសអន្តរក្រសួងប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម (ក.ប.ស.ហ) បានសហការរៀបចំយុទ្ធសាស្ត្រជាតិស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម ឆ្នាំ២០១៩-២០២៣ ដោយមានការណែនាំពី គ.ស.ហ និងមានជំនួយបច្ចេកទេសពីមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ដើម្បីប្រើប្រាស់ជាមគ្គុទ្ទេសក៍រយៈពេលវែងដ៏ពេញលេញមួយរបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ យុទ្ធសាស្ត្រជាតិនេះមានគោលបំណងចម្បងបំផុត ដើម្បី ១/- ឲ្យគ្រឹះស្ថានហិរញ្ញវត្ថុ និងមុខរបរនិងវិជ្ជាជីវៈមិនមែនហិរញ្ញវត្ថុគេចផុតពីការប្រើប្រាស់ក្នុងការសម្អាតប្រាក់និងស្វែងរកផលនៃបទល្មើស និងទ្រព្យសម្បត្តិពាក់ព័ន្ធនឹងហិរញ្ញប្បទានភេរវកម្ម និង២/- ធានាឲ្យអាជ្ញាធរអនុវត្តច្បាប់ទាំងអស់រួមគ្នាធ្វើការស៊ើបអង្កេត ចោទប្រកាន់ ដាក់ទណ្ឌកម្ម និងរឹបអូសផលនិងឧបករណ៍នៃសំអាងបទល្មើស និងបទសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មប្រកបដោយប្រសិទ្ធភាព។



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

នាឱកាសនេះ ឯកឧត្តម **ជា ចាន់តូ** ទេសាភិបាលធនាគារជាតិនៃកម្ពុជា និងជាប្រធាន គ.ស.ហ បានមានប្រសាសន៍ពាក់ព័ន្ធនឹងគោលបំណងគន្លឹះជាយុទ្ធសាស្ត្រចំនួន ១០ របស់យុទ្ធសាស្ត្រជាតិ និងសកម្មភាពការងារកំណត់តាមអាទិភាព និងពេលវេលាច្បាស់លាស់ ដែលក្រសួង-ស្ថាប័នពាក់ព័ន្ធត្រូវសហការរួមគ្នាជាមួយវិស័យឯកជនសម្រេចឲ្យបាន ដើម្បីធានាបាននូវប្រសិទ្ធភាពនៃប្រព័ន្ធប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មនៅប្រទេសកម្ពុជា និងជាពិសេសឆ្លើយតបនឹងហានិភ័យថ្នាក់ជាតិស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ដែលបានវាយតម្លៃកាលពីឆ្នាំ២០១៦ និងអនុសាសន៍ដែលបានកំណត់ក្នុងរបាយការណ៍វាយតម្លៃអញ្ញមញ្ញស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ឆ្នាំ២០១៧ ផងដែរ។

គ.ស.ហ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួង-ស្ថាប័ន និងភាគីពាក់ព័ន្ធទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតម្លៃ សហការរៀបចំ ផ្តល់ធាតុចូល និងចែករំលែកបទពិសោធន៍ការងារជាពិសេសមូលនិធិរូបិយវត្ថុអន្តរជាតិ ដែលបានផ្តល់ជំនាញការ និង Thematic Trust Fund ដែលបានផ្តល់ជំនួយហិរញ្ញវត្ថុ ក្នុងការរៀបចំឯកសារយុទ្ធសាស្ត្រជាតិនេះឡើងប្រកបដោយជោគជ័យ និងរួមគ្នាអនុវត្តឲ្យមានប្រសិទ្ធភាព។

**អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា**